S9BO7617-10
ខែធ្នូ ឆ្នាំ 2021

# កូនសៀវភៅណែនាំ ដំណើរការ និងការថែទាំជួសជុល

## គ្រឿងភ្ជាប់លឿនផ្លូបគ្នា

A8K 1-UP (គ្រឿងភ្ជាប់លឿន)
L9A 1-UP (គ្រឿងភ្ជាប់លឿន)
PA2 1-UP (គ្រឿងភ្ជាប់លឿន)
Y7A 1-UP (គ្រឿងភ្ជាប់លឿន)
Y8B 1-UP (គ្រឿងភ្ជាប់លឿន)
ZTS 1-UP (គ្រឿងភ្ជាប់លឿន)

ភាសា៖ សេចក្ដីណែនាំដើម

ស្កេនដើម្បីស្វែងរក និងទិញគ្រឿងបន្លាស់ពិតរបស់ Cat® និងព័ត៌មានសេវាកម្មដែលពាក់ព័ន្ធ។

i07966018

# ព័ត៌មានអំពីសុវត្ថិភាពសំខាន់ៗ

គ្រោះថ្នាក់ភាគច្រើនដែលពាក់ព័ន្ធនឹងប្រតិបត្តិការគ្រឿងចក្រ ការថែទាំ និងការជួសជុល គឺបណ្ដាលមកពីការមិនគោរពវិធានសុវត្ថិភាពជាមូលដ្ឋាន ឬការប្រុងប្រយ័ត្នជាមុន។ ជារឿយៗ គ្រោះថ្នាក់អាចជៀសវាងបានតាមរយៈការដឹងពីស្ថានភាពដែលអាចបង្កគ្រោះថ្នាក់ មុនពេលគ្រោះថ្នាក់កើតឡើង។ គេត្រូវតែប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់ដែលអាចកើតឡើង ដែលរួមមានកត្តាមនុស្សដែលអាចប៉ះពាល់ដល់សុវត្ថិភាព។ មនុស្សម្នាក់នេះក៏គួរមានការបណ្ដុះបណ្ដាលជំនាញ និងមានឧបករណ៍ដែលចាំបាច់ ដើម្បីបំពេញមុខងារទាំងនេះឲ្យបានត្រឹមត្រូវផងដែរ។

**ប្រតិបត្តិការ ការដាក់ប្រេងរំអិល ការថែទាំ ឬការជួសជុលគ្រឿងចក្រមិនបានត្រឹមត្រូវ អាចបង្កគ្រោះថ្នាក់ ហើយអាចបណ្ដាលឲ្យមានរបួស ឬស្លាប់។**

**មិនត្រូវធ្វើប្រតិបត្តិការ ឬធ្វើការដាក់ប្រេងរំអិល ការថែទាំ ឬការជួសជុលចំពោះគ្រឿងចក្រនេះឡើយ រហូតដល់អ្នកបញ្ជាក់ថា អ្នកត្រូវបានអនុញ្ញាតឲ្យអនុវត្តការងារនេះ ហើយបានអាននិងយល់ពីព័ត៌មានអំពីប្រតិបត្តិការ ការដាក់ប្រេងរំអិល ការថែទាំ និងការជួសជុល។**

ការប្រុងប្រយ័ត្ន និងការព្រមានជាមុនអំពីបញ្ហាសុវត្ថិភាព ត្រូវបានផ្ដល់នៅក្នុងសៀវភៅណែនាំនេះ និងនៅលើគ្រឿងចក្រ។ ប្រសិនបើមិនយកចិត្តទុកដាក់ចំពោះការព្រមានអំពីគ្រោះថ្នាក់ទាំងនេះ របួសរាងកាយ ឬស្លាប់អាចនឹងកើតមានឡើងចំពោះអ្នក ឬអ្នកដទៃ។

គ្រោះអន្តរាយនានាត្រូវដាក់សម្គាល់ដោយ "រូបសញ្ញាប្រុងប្រយ័ត្នអំពីសុវត្ថិភាព" និងបន្ទាប់មកដោយ "ពាក្យសញ្ញា" ដូចជា "DANGER (គ្រោះថ្នាក់)" "WARNING (ព្រមាន)" ឬ "CAUTION (ប្រយ័ត្ន)" ។ ស្លាក "WARNING" (ការព្រមាន) ឲ្យប្រយ័ត្នអំពីសុវត្ថិភាព ត្រូវបានបង្ហាញខាងក្រោម។

**⚠ ការព្រមាន**

អត្ថន័យនៃនិមិត្តសញ្ញាឲ្យប្រយ័ត្នអំពីសុវត្ថិភាពនេះមានដូចខាងក្រោម៖

**ប្រយ័ត្ន! សូមប្រយ័ត្ន! អាចប៉ះពាល់សុវត្ថិភាពរបស់អ្នក។**

សារដែលលេចឡើងខាងក្រោមសេចក្ដីព្រមាន ពន្យល់អំពីគ្រោះថ្នាក់ និងអាចជាសំណេរ ឬជារូបភាព។

បញ្ជីមិនពេញលេញស្ដីពីប្រតិបត្តិការទាំងឡាយដែលអាចបណ្ដាលឲ្យខូចផលិតផល ត្រូវបានសម្គាល់ដោយស្លាក "NOTICE" ដែលស្ថិតនៅលើផលិតផលនោះ និងនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ។

**ក្រុមហ៊ុន Caterpillar មិនអាចរៀបរាប់អំពីស្ថានភាពដែលអាចបង្កគ្រោះថ្នាក់ទាំងអស់បានឡើយ។ ដូចនេះ ការព្រមាននៅក្នុងឯកសារបោះពុម្ពផ្សាយនេះ និងការព្រមាននៅលើគ្រឿងចក្រ មិនបានរួមបញ្ចូលគ្រប់ស្ថានភាពទាំងអស់ទេ។ អ្នកមិនត្រូវប្រើគ្រឿងចក្រនេះតាមវិធីណាមួយខុសពីអ្វីដែលបានណែនាំនៅក្នុងកូនសៀវភៅណែនាំនេះឡើយ លុះត្រាតែអ្នកច្បាស់ក្នុងចិត្តជាមុនថា អ្នកបានគិតពិចារណាលើវិធាន និងការប្រុងប្រយ័ត្នអំពីសុវត្ថិភាពទាំងអស់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការគ្រឿងចក្រនេះនៅទីតាំងប្រើប្រាស់នីមួយៗ រួមទាំងវិធាន និងការប្រុងប្រយ័ត្នអំពីសុវត្ថិភាពនៅតាមទីតាំងជាក់លាក់នៅក្នុងការដ្ឋាន។ ប្រសិនបើឧបករណ៍ ទម្រង់ការ វិធីសាស្ត្រធ្វើការងារ ឬបច្ចេកទេសប្រតិបត្តិការមិនទទួលបានការណែនាំជាក់លាក់ពី Caterpillar ទេ លោកអ្នកត្រូវតែប្រាកដដោយខ្លួនឯងថា វាមានសុវត្ថិភាពចំពោះលោកអ្នក និងអ្នកដទៃ។ លោកអ្នកក៏ត្រូវប្រាកដដែរថា លោកអ្នកត្រូវបានអនុញ្ញាតឲ្យអនុវត្តការងារនេះ ហើយក៏ត្រូវធានាទៀតដែរថា គ្រឿងចក្រនឹងមិនខូច ឬក៏គ្មានសុវត្ថិភាពដោយសារប្រតិបត្តិការ ការដាក់ប្រេងរំអិល ការថែទាំ ឬវិធីជួសជុលដែល លោកអ្នកចង់ធ្វើផងដែរ។**

ព័ត៌មាន លក្ខណៈបច្ចេកទេស និងរូបភាពនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ គឺជាព័ត៌មានមូលដ្ឋានដែលមាននៅពេលចងក្រងឯកសារបោះពុម្ពផ្សាយ។ លក្ខណៈបច្ចេកទេស តំណឹង សម្ពាធ រង្វាស់ ការលៃតម្រូវ រូបភាព និងចំណុចផ្សេងទៀត អាចត្រូវបានផ្លាស់ប្ដូរគ្រប់ពេលវេលា។ ការផ្លាស់ប្ដូរទាំងនេះអាចប៉ះពាល់ដល់សេវាកម្មគ្រឿងចក្រដែលបានផ្ដល់ជូន។ សូមស្វែងយល់ឲ្យបានច្បាស់លាស់ និងទទួលយកព័ត៌មានថ្មីៗបំផុត នៅមុនពេលអ្នកចាប់ផ្ដើមការងារណាមួយ។ អ្នកចែកចាយ Cat មានព័ត៌មានថ្មីៗបំផុត។

---

សម្គាល់

**ពេលត្រូវការផ្លាស់ប្ដូរគ្រឿងបន្លាស់សម្រាប់ផលិតផលនេះ Caterpillar សូមណែនាំឲ្យប្រើប្រាស់គ្រឿងបន្លាស់របស់ Caterpillar។**

**ផ្នែកដទៃទៀតអាចមិនឆ្លើយតបតាមព័ត៌មានលម្អិតគ្រឿងបរិក្ខារដើមមួយចំនួន។**

**នៅពេលប្ដូរគ្រឿង ម្ចាស់/អ្នកប្រើប្រាស់ម៉ាស៊ីនគួរតែប្រាកដថាម៉ាស៊ីននៅតែអនុលោមតាមសេចក្ដីតម្រូវដែលអាចអនុវត្តបានទាំងអស់។**

---

**នៅសហរដ្ឋអាមេរិក ការថែទាំ ការប្ដូរគ្រឿងបន្លាស់ ឬការជួសជុលឧបករណ៍ និង ប្រព័ន្ធគ្រប់គ្រងការបំភាយផ្សែង អាចធ្វើឡើងដោយគ្រឹះស្ថានជួសជុលណាមួយ ឬបុគ្គលណាម្នាក់តាមការជ្រើសរើសរបស់ម្ចាស់គ្រឿងចក្រ។**

# តារាងមាតិកា

បុព្វកថា ........................................................................4

## ផ្នែកសុវត្ថិភាព

សារសុវត្ថិភាព ..................................................................5

ព័ត៌មានអំពីគ្រោះអន្តរាយទូទៅ.............................................7

ការបង្ការការបុកទង្គិច និងការកាត់9.........................................

ការបង្ការការរលាក.......................................................... 10

ការបង្ការអគ្គិភ័យនិងការផ្ទុះ .............................................. 10

នៅមុនការធ្វើប្រតិបត្តិការ .................................................. 12

ប្រតិបត្តិការ.................................................................... 12

ព័ត៌មានអំពីសំឡេងនិងរំញ័រ .............................................. 14

## ផ្នែកព័ត៌មានអំពីផលិតផល

ព័ត៌មានទូទៅ ................................................................ 15

ព័ត៌មានអត្តសញ្ញាណ...................................................... 18

## ផ្នែកប្រតិបត្តិការ

ប្រតិបត្តិការ.................................................................... 22

ព័ត៌មានអំពីការដឹកជញ្ជូន35..................................................

## ផ្នែកថែទាំ

ការគាំទ្រការថែទាំ36............................................................

កាលវិភាគចន្លោះពេលថែទាំ .............................................. 37

## ផ្នែកព័ត៌មានយោង

ឯកសារយោង ................................................................ 40

## ផ្នែកលិបិក្រម

លិបិក្រម ........................................................................ 41